MEKONG RIVER COMMISSION
MRC
FOR SUSTAINABLE DEVELOPMENT

# Catch and Culture

## ការអភិវឌ្ឍន៍ និងការសិក្សាស្រាវជ្រាវវិស័យជលផលនៅក្នុងតំបន់ទន្លេមេគង្គ

ភាគទី ១០ លេខ ១-២ ISSN 0859-290X ខែ មេសា ឆ្នាំ ២០០៥





### សារៈសំខាន់នៃចំណុចនីមួយៗ


- ទឹកហូរតិច តម្លៃត្រីខ្ពស់
- ទិសដៅអភិវឌ្ឍន៍ដាយត្រីអាជីវកម្មរបស់ប្រជាជនកម្ពុជា
- គំរូសំណាកកូនត្រី
- សារៈសំខាន់ព្រុយរបស់ត្រី
- ត្រីខ្ទីង(ត្រីអន្ទង់) និងការព្រលែងចូលទៅក្នុងទន្លេ ម៉ុន
- ការបរិភោគត្រីដែលបណ្តាលឱ្យស្លាប់នៅក្នុងពិធីបុណ្យ
- ការប្រមូលផលវិលជុំបណ្តាក់
- ការផ្លាស់ប្តូរការងារមន្ត្រីនៅគណៈកម្មការទន្លេមេគង្គ

លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គបានបោះពុម្ពកំរងសៀវភៅ "*ការចិញ្ចឹម និងការចាប់ Catch and Culture*" ចំនួនបីលើកក្នុងមួយឆ្នាំនៅក្នុងទីក្រុងភ្នំពេញប្រទេសកម្ពុជា និងបានចែកចាយទៅកាន់អ្នកជាវជាង ៦៥០ នាក់នៅជុំវិញពិភពលោក ។ ព័ត៌មានជាច្រើនស្ដីអំពី "*ការចិញ្ចឹម និងការចាប់*" អាចរកបានដោយសេរីតាមរយៈវេបសាយ (Website,WWW.mrcmekong.org) ដែលមានការយល់ព្រមដោយគណៈកម្មការទន្លេមេគង្គ និងព័ត៌មានតម្លៃលើកំរងសៀវភៅនេះអាចរកបានពីមជ្ឈមណ្ឌលឯកសាររបស់លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គតាមរយៈសំបុត្រទៅកាន់: doc.centre@mrcmekong.org ។

សប្បុរសជនដែលមានបំណងបរិចាកវិភាគទានសំរាប់ទ្រទ្រង់កំរងសៀវភៅ "*ការចិញ្ចឹម និងការចាប់*"
អាចផ្ញើទៅកាន់លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គតាមរយៈ mrcs@mrcmekong.org ។

© គណៈកម្មការទន្លេមេគង្គ ២០០៤





**សមាសភាពក្រុមបណ្ណាធិការជាភាសាអង់គ្លេស**

លោកបណ្ឌិត *គ្រីស បាឡូ* (Chris Barlow): នាយកកម្មវិធីជលផលនៃគណៈកម្មការទន្លេមេគង្គ

លោកបណ្ឌិត *ង្វៀន គួកអាន* (Nguyen Quoc An): មន្ត្រីកម្មវិធីជលផលនៃគណៈកម្មការទន្លេមេគង្គ

លោក *ខឹមតាន់ វត្ថានាថាម* (Khamtanh Vatthanatham): មន្ត្រីកម្មវិធីជលផលនៃគណៈកម្មការទន្លេមេគង្គ និង

លោក *វីយីនី អេតឌីសុន* (Virginia Addison): មន្ត្រីទំនាក់ទំនងលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ

**សមាសភាពក្រុមបណ្ណាធិការជាខេមរៈភាសា**

លោក *សម នៅ* អនុប្រធាននាយកដ្ឋានជលផល

លោក *ម៉ៅ សំអុន* មន្ត្រីជំនួយការថ្នាក់ដឹកនាំនាយកដ្ឋានជលផល

**អ្នកបោះពុម្ពផ្សាយ** : លោក *ភិតធី ស្តា* (Peter Starr)

**ការតាក់តែង និងរចនាគំរប** : លោក *សូ សាវ៉ាក់*

**បកប្រែដោយៈ** លោក *សេង ម៉ូហិក* មន្ត្រីកម្មវិធីជំនួយការ កម្មវិធីជលផលនៃលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ





# សារលិខិតពីនាយកប្រតិបត្តិ (CEO)

ជលផលនៃអាងទន្លេមេគង្គខាងក្រោម ( ប្រសិនបើគ្មានបញ្ហា) គឺ ផ្តល់នូវសារៈសំខាន់ដល់ប្រជាជន ១០ លាននាក់ដែលពឹងផ្អែកទៅលើត្រីដែលជាប្រភពប្រាក់ចំណូល និងអាហារដ៏មានសារៈសំខាន់។ តាមពិតវាត្រូវបានគេប៉ាន់ស្មានថា ទិន្នផលត្រី វារីសត្វបច្ចុប្បន្ននៅក្នុងអាងទន្លេមេគង្គខាងក្រោមគឺ មានប្រមាណ ៣ លានតោន ក្នុងមួយឆ្នាំ។ នេះគឺ ជាធនធានមួយដ៏មានសារៈសំខាន់ធំក្រៃលែង ប៉ុន្តែវិស័យនេះគឺ ស្ថិតនៅក្រោមការនេសាទយ៉ាងខ្លាំង។ យើងមើលឃើញបញ្ហានេះតាមរយៈការខិតខំប្រឹងប្រែងការនេសាទដែលកំពុងតែមានការកើនឡើងយ៉ាងឆាប់រហ័សនៅក្នុងអាងទន្លេដោយទូទៅជាញឹកញាប់ពួកគេបានអនុវត្តការនេសាទដោយខុសច្បាប់ ដែលត្រូវគេធ្វើការពិភាក្សានៅក្នុង *ការចាប់ និងការចិញ្ចឹម* ។ ការគ្រប់គ្រងវិស័យជលផលចាំបាច់នឹងត្រូវធ្វើឱ្យប្រសើរឡើងដើម្បីកាត់បន្ថយផលប៉ះពាល់ការនេសាទខុសច្បាប់ និងការនេសាទលើសលប់។ ការគំរាមកំហែងដោយប្រយោលផ្សេងទៀតទៅលើវិស័យជលផលដូចជា ការបាត់បង់ទីជំរក ការបញ្ជាក់ពីគុណភាពទឹក និងការគ្រប់គ្រងទៅលើទំហំនៃសេចក្តីត្រូវការ។

នៅក្នុងពេលដំនាលគ្នានេះយើងចាំបាច់ត្រូវយល់ថា ការប្រើប្រាស់ទឹកទន្លេមេគង្គក្រៅពីវិស័យជលផលគឺ ត្រូវតែឱ្យសមស្របតាមច្បាប់។ ដូចជាបញ្ហា ការស្រោចស្រពទៅលើកសិកម្ម ការផលិតថាមពលអគ្គិសនី ការធ្វើនាវាចរ និងការផ្គត់ផ្គង់ទឹកជាលក្ខណៈឧស្សាហកម្ម និងក្នុងស្រុក។ ពីវិស័យជលផលនិងភារកិច្ចរៀង១ខ្លួនគឺ ការចាប់ដៃជាមួយដៃគូជាច្រើនមកពីវិស័យផ្សេង១ជាច្រើនសំរាប់អ្នករៀបចំវិស័យជលផល និងបញ្ហាកាបន្ធូរបន្ថយអត្តសញ្ញាណដែលនឹងធ្វើឱ្យមានសុទិដ្ឋិនិយមផលិតផលជលផលក្នុងខណៈពេលដែលការយល់ព្រមសំរាប់ផលប្រយោជន៏ការអភិវឌ្ឍន៏ដែលនឹងត្រូវគេចែករំលែកទៅតាមលទ្ធិភាពដែលអាចកើតឡើងជាច្រើន។

ប្រសិនបើយើង មានគោលបំណងចង់ដឹង និងចង់បញ្ចប់ភាពក្រីក្រនៅក្នុងតំបន់ទន្លេមេគង្គទាំងនេះ យើងត្រូវតែក្រលេកទៅមើលមធ្យោបាយជាច្រើននៃការជ្រើសរើសដែលកំពុងធ្វើឡើងនិងការប្រើប្រាស់ទឹកនៃទន្លេមេគង្គប្រកបដោយនិរន្តភាព។ ខ្ញុំដឹងថាតួនាទីរបស់គណៈកម្មការទន្លេមេគង្គជាផ្នែកមួយនៃការសំរបសំរួលច្រើនជាងការអភិវឌ្ឍន៏និងការវិនិយោគនៅក្នុងផ្នែកជាច្រើនដែលទាក់ទងទៅនិងការប្រើប្រាស់ទឹកទាំងអស់ រួមមានទាំងវិស័យជលផលផងដែរ។

ការអភិវឌ្ឍន៏ប្រភពទឹកអាងទន្លេឱ្យកាន់តែធំឡើងជាអន្តរជាតិដោយមិនមានការលំបាកនិងភាពប្រថុយប្រថាន។ ប៉ុន្តែជាមួយនឹងការសហការរួមគ្នានឹងដែលមានផលប្រយោជន៏ដោយផ្អែកទៅលើកិច្ចសហប្រតិបត្តិការជិតស្និទ្ធិរវាងផ្នែកជាច្រើន និងរវាងប្រទេសជាច្រើន យើងអាចរកមើលនៅដំណោះស្រាយដែលសង្គម និងបរិស្ថានអាចទទួលយកបានសំរាប់បញ្ហាខ្លះនៃការប្រឡងប្រណាំងដែលកំពុងតែប្រឈមមុខនឹងវិស័យជលផលផ្ទាល់ និងអាងទន្លេ។ រាល់ការអភិវឌ្ឍន៏ទាំងឡាយនេះអាចបានជាផលប្រយោជន៏រួមសំរាប់ប្រជាជនដែលរស់នៅតាមដងទន្លេមេគង្គ ជាពិសេសសំរាប់ជនក្រីក្រ។

Dr Oliver Cogels
Chief Executive Officer
Mekong River Commission

# លក្ខណៈចុះទាបនៃទឹក

ដោយ *ភិតធី ស្តា* ( Peter Starr )

ស្របទៅតាមរបាយទឹកភ្លៀងធ្លាក់ទាបខុសពីធម្មតាកាលពីឆ្នាំមុន និងអំឡុងរដូវប្រាំងឆ្នាំនេះកំរិតទឹកទន្លេមេគង្គត្រូវបានគេកត់ត្រាថា មានកំរិតទាបបំផុតក្នុងអំឡុង ៤៤ ឆ្នាំចុងក្រោយនេះ។ការចាប់ត្រីបានធ្លាក់ចុះពាក់កណ្តាលនៅក្នុងតំបន់មួយចំនួននៃប្រទេសកម្ពុជា រួមមានទាំងបឹងទន្លេសាបដែលបានរាយការណ៍ថា ដោយអាជីវកម្មនេសាទត្រីទើបតែទទួលរងនូវការគំរាមកំហែងពីរដូវរាំងស្ងួតរបស់វាដែលបណ្តាលឱ្យតម្លៃត្រីបានឡើងយ៉ាងខ្ពស់។

អ្នកស្រី *សៀង កុំសឹង* ដែលស្ថិតនៅលើទូកដែលជាផ្ទះរបស់គាត់បានជំរាបសួរទៅកាន់អ្នកនេសាទក្មេងៗដែល កំពុងកាន់ត្រីរស់ជាច្រើន និងមានតម្លៃខ្ពស់ដែលគេចាត់ទុកថា ជាផលិតផលល្អប្រណិតនៃអាស៊ីខាងកើតផងនោះ (*Oxyeleotris marmorata* )ជាពិសេស ក្នុងចំណោមប្រជាជនចិន។ មុខរបរធ្វើអាជីវកម្មត្រីរបស់ប្រជាជនកម្ពុជាគឺ ជាមុខរបរមួយសមរម្យសំរាប់ពួកគេដូចជាវេចខ្ចប់ និងដាក់ផ្លាកសំគាល់ទៅលើឡាំងរួចហុចបន្តទៅឱ្យបុរសរៀបចំបន្តដាក់ចូលក្នុងឡាំង សំរាប់នាំទៅ ហុងកុង និង សាំងកាប៉ូ ត្រីដំរីដែលភាសាចិនហៅថា ស៊ុនគីយូ (Shunke yu) ។ អ្នកស្រី ***សៀង កុំសឹង*** ដែលសព្វថ្ងៃ រស់នៅភូមិដែលមានទូកជាច្រើនរយធ្វើជាផ្ទះបណ្តែតទឹកតាមមាត់ទន្លេនៃភូមិកណ្តាលនៃទីក្រុងខេត្តកំពង់ឆ្នាំង បានសង្កេតឃើញកំរិតទឹកទន្លេទាបបំផុតក្នុងចំណោមពីមុនមកដែលគាត់បានឃើញពេលនេះ។ គាត់បានបន្តទៀតថា ឥឡូវនេះទំហំនៃការរកស៊ីរបស់គាត់បានធ្លាក់ចុះ ៥០% ។ មន្ត្រីជលផលមូលដ្ឋានជាច្រើនរូបបាននិយាយអំពីបញ្ហានេះ " ខេត្តកំពង់ឆ្នាំង " ស្រដៀងគ្នាទៅនឹងតំបន់ផ្ទុកទ្រូវដែលមានប្រជាជន



១.៧០០ គ្រួសារកំពុងរស់នៅក្នុងភូមិបណ្តែតទឹកមួយ ដែលលាតសន្ធឹងនៅក្បែរបឹងទន្លេសាប។ កំរិតទឹកទន្លេនៅពាក់កណ្តាលខែមីនាឆ្នាំនេះគឺ ទាបជាងពាក់កណ្តាលក្នុងរយៈពេលដូចគ្នាកាលពីឆ្នាំមុន "វាជាឆ្នាំមួយដែលមានការរាំងស្ងួតយ៉ាងខ្លាំងដែលខ្ញុំបានឃើញចាប់តាំងពីឆ្នាំ ១៩៨៧ ហើយពេលនោះយើងអាចដើរឆ្លងផ្ទះជាច្រើនបាន" ដែលបាននិយាយដោយអ្នកមានលំនៅដ្ឋានជាអចិន្ត្រៃនៅទីនោះ។ ឆ្នុកទ្រូជាកន្លែងសំខាន់ដែលមានជម្រៅទឹកជ្រៅរាល់រដូវ សំរាប់កប៉ាល់នេសាទមកពីខេត្ត ៩ នៅជំវិញបឹងទន្លេសាប នឹងដែលមានចំនួនទូកនេសាទ ៤០០ ទូក កំពុងប្រកបរបរនេសាទជារៀងរាល់ប្រចាំថ្ងៃរបស់ពួកគេ និងការដឹកជញ្ជូនទំនិញឆ្លងកាត់ដីមានសារៈសំខាន់ផងដែរ។ មន្ត្រីជលផលបាននិយាយថា ជាធម្មតាការនេសាទមានចំនួន ៨ ខែដែលគិតចាប់តាំងពីខែ មីនា ប៉ុន្តែក្នុងរយៈពេលនោះមានចំនួនពីរខែ ដែលមានការនេសាទបន្តិចបន្តួចពីព្រោះទំហំនៃការនេសាទបានធ្លាក់ចុះ ៥០ % ពីរដូវនេសាទមុន។ ដោយសារទឹកភ្លៀងធ្លាក់តិចតួចខុសពីធម្មតាកាលពីឆ្នាំមុន និងកំរិតទឹកទន្លេនៅទាបប្រជាជនបង្អង់ក្នុងការចេញទៅនេសាទ នាំឱ្យការចាប់បានតិចតួច និងតម្លៃត្រីមានការកើនឡើងជាបន្តបន្ទាប់។ ជាមួយនឹងអត្រានៃការផ្គត់ផ្គង់ត្រីយ៉ាងខ្ពស់ ដែលមានរហូតដល់ ៥០ គ.ក្រ. ក្នុងមួយឆ្នាំនៃតំបន់ជា ពិសេសសំរាប់ការរស់នៅរបស់ប្រជាជននៅក្នុងតំបន់ទំនាបលិចទឹក និងដីសន្តរនៅក្នុងប្រទេសវៀតណាមដែលអាចទទួលរងនូវអំពើគ្រប់យ៉ាងបាន។ ទោះបីយ៉ាងណាក៏ដោយសំរាប់អ្នកដែលមានចំនួលបានបន្តិចបន្តួចពីការនេសាទដែលជាផ្នែកមួយដែលបានមកពីការទូទាត់ដោយសារតែតម្លៃត្រីកើនឡើង។ អ្នកស្រី ***សៀង កុំស៊ីង*** បាននិយាយថា តម្លៃត្រីដំរីសំរាប់ទំហំមធ្យមបានកើនឡើងទ្វេរពី ៦.០០០៛ (1,50$)រហូតដល់ ១៥.០០០ ៛ (3,75$) ក្នុងមួយគីឡូក្រាមនៅក្នុងខែមីនាដើមឆ្នាំ។ ចំពោះតម្លៃត្រីប្រភេទតូចៗដែលមានទំងន់ ២០០ក្រាម អាចលក់បានខ្ពស់ជាង៤.០០០៛/១ គ.ក្រ.គឺ មានរហូតដល់ ៦០ % និងត្រីដែលមានទំងន់ចាប់ពី ១ គ.ក្រ. ឡើងទៅអាចលក់បានខ្ពស់ជាង ៣៥.០០០៛/១ គ.ក្រ គឺ មានរហូតដល់ ៤០% ដោយឡែកចំពោះតម្លៃត្រីប្រភេទផ្សេងទៀតគឺ មានកំរិតទាបយ៉ាងខ្លាំង។ មន្ត្រីជលផលនៅឆ្នុកទ្រូបាននិយាយថា ប្រភេទត្រីកាបទន្លេតូចៗដែលអ្នកស្រុកហៅថា ត្រីរៀលគឺមានតម្លៃបានត្រឹមតែពី១០០៛- ១០០០៛(25cents)/១ គ.ក្រ. នៅក្នុងខែមីនាដើមឆ្នាំ។ ការបំលាស់ទីនៃប្រភេទត្រីតូចៗទាំងនេះគឺ ជាការផ្តល់នៅចំណែកមួយយ៉ាងសំខាន់ចំពោះប្រជាជនខ្មែរចាប់សំរាប់ធ្វើការកែច្នៃដូចជា ប្រហុក ផ្អក និងទឹកត្រី ជាដើម។ គេបានគណនាប្រភេទត្រីជាច្រើនប្រភេទប្រហែលជាពាក់កណ្តាលនៃការចាប់ត្រីប្រចាំឆ្នាំនៃដាយត្រីអាជីវកម្មរបស់បឹងទន្លេសាប មានទីតាំងចុងទឹកស្ថិតនៅក្បែររាជធានីភ្នំពេញដែលជាចំណុចប្រសព្វនៃទន្លេមេគង្គ ការចាប់ត្រីឆ្នាំនេះគឺ មានចំនួន ៦.៥៥០តោន ទាបជាង ៤៧% ពីចំនួន ១២.៤២៧តោនកាលពីដើមឆ្នាំគឺ ទាបជាងសេចក្តីរាយការណ៍ (មើលនៅទំព័រទី ៧ ដែលបានភ្ជាប់ជាមួយ) លោកបណ្ឌិត *គ្រិស្ត បាឡូ*(Chris Barlow) ជាអ្នកគ្រប់គ្រងកម្មវិធីជលផលរបស់គណៈកម្មការទន្លេមេគង្គបានមានការចាប់អារម្មណ៍យ៉ាងខ្លាំង ទៅលើការចាប់ត្រីដែលបានធ្លាក់ចុះក្នុងប្រទេសកម្ពុជា។ គាត់បានបន្តថា " ផលត្រីដែលចាប់បានកំពុងមានការថយចុះគួរឱ្យព្រួយបារម្ភណ៍ "។ ដែលបញ្ហានេះវាបណ្តាលមកពីមានទឹកជំនន់តូច និងរយៈពេលខ្លីកាលពីរដូវវស្សាឆ្នាំមុន និងមានការអះអាងបញ្ជាក់ជាច្រើនផងដែរ ដែលបញ្ហានេះបណ្តាលមកពីមានការជាប់ពាក់ព័ន្ធទៅនឹងការនេសាទដីលើសលប់។ ការរកត្រីបានបន្តិចបន្តួចធ្វើឱ្យតម្លៃត្រីនៅទីផ្សារមានការកើនឡើង គួរឱ្យព្រួយបារម្ភណ៍ដែលបានជះឥទ្ធិពលយ៉ាងខ្លាំងដល់ការរស់នៅដែលអាស្រ័យទៅលើត្រីសំរាប់ផ្គត់ផ្គង់ការរស់នៅរបស់ពួកគេនៅឯជនបទ។" បញ្ហាសំខាន់ៗដែលបានលើកឡើងគឺ វា

ទាក់ទងជាមួយទឹកដែលហូរនៅក្នុងទន្លេ ផលិតផលត្រី និងការប្រកបមុខរបររបស់គាត់នៅឯជនបទ"។ មន្ត្រីជលផលខេត្តកំពង់ឆ្នាំងបានកត់សំគាល់ថា ប្រព័ន្ធបឹងទន្លេសាបដែលគេដឹងថា កាន់តែរីងទៅៗពីមួយឆ្នាំទៅមួយឆ្នាំដូចជា ទីជំរកព្រៃលិចទឹកដែលជាប្រភពដ៏សំបូរសំរាប់ត្រីផ្លាស់ទីមករកចំណី ។ នៅរដូវវស្សាតំបន់ព្រៃលិចទឹកសំខាន់ៗជាច្រើនរបស់បឹងទន្លេសាបអាចលាតសន្ធឹងចាប់ពី ៤ ដល់ ៦ ដងធំជាងតំបន់ក្នុងរដូវប្រាំងរបស់វា។ ដូចជានៅឆ្នាំ ២០០៣ ដែលជាឆ្នាំមានការរាំងស្ងួតខ្លាំងបានធ្វើឱ្យប៉ះពាល់ដោយផ្ទាល់ការរកចំណីសំរាប់កូនត្រី និងការពងកូនរបស់ត្រីដែលគ្រប់អាយុ។ មន្ត្រីជលផលខេត្តបាននិយាយថា ការចាប់ត្រីឆ្នាំនេះមានការប៉ះពាល់យ៉ាងខ្លាំងពីព្រោះពួកគេនៅតែអនុវត្តរំលោភច្បាប់ដូចជា ការប្រើប្រាស់ឧបករណ៍នេសាទស្បៃមុង និងឧបករណ៍ឆក់ជាដើមដែលបណ្តាលឱ្យប៉ះពាល់ដល់កូនត្រីតូចៗ និងធ្វើឱ្យរបួសដល់ត្រីធំៗ ល្មម។ មន្ត្រីជលផលនៅឆ្នុកទ្រូមួយរូបបាននិយាយថា ឆ្នាំនេះប្រជាជនបានកំពុងប្រើប្រាស់ ឧបករណ៍ស្បៃម៉ុង យ៉ាងច្រើនរហូតមកដល់ពេលនេះមាន ២២ ករណីផ្សេងទៀតដែលត្រូវបានចាប់ឃាត់ខ្លួនពីបទសង្ស័យបានលួចនេសាទខុសច្បាប់នៅឆ្នាំនេះ និងបានធ្វើការដកហូតស្បៃម៉ុងប្រវែងជាង ២ គីឡូម៉ែត្រ។ ថ្មីនេះលោក *ឡែន កំបែល* (Lan Campbell) ជាអ្នកជំនាញខាងបរិស្ថាន នឹងបានរួមជាមួយគណៈកម្មការទន្លេមេគង្គ បានបដិសេធរបាយការណ៍រិះគុណលើទំនប់វារីអគ្គិសនីរបស់ប្រទេសចិនដែលបានធ្វើឱ្យកំរិតទឹកទន្លេឆ្នាំនេះចុះទាប និងបានបន្តទៀតថា កំរិតទឹកដែលបានកាត់បន្ថយគឺ វាមានទំនាក់ទំនងយ៉ាងច្បាស់ទៅ និងរបាយទឹកភ្លៀងទាបកាលពីរដូវវស្សាឆ្នាំមុន។ លោក *កំ បែល* បាននិយាយថា "ប្រសិនបើយើងក្រឡេកមើលទៅលើបញ្ហានៃការចាប់ត្រីពី ខែ មិថុនា ដល់ ខែ កញ្ញាគឺ នៅពេលនោះវាបានចាប់ផ្តើមកើតមានបញ្ហារួចទៅហើយ"។ ដោយផ្អែកលើព័ត៌មានលើកមុនរបស់គណៈកម្មការទន្លេមេគង្គដែលបានកំណត់យក ១៦ កន្លែងសំរាប់ធ្វើការសិក្សា និងការចេះដឹងផ្សេងៗទៀតគឺ តួលេខជាច្រើនបានបង្ហាញយ៉ាងច្បាស់ថា ចំនួនរបាយទឹកភ្លៀងដែលបានស្ទង់ឃើញទាបខុសពីធម្មតាក្នុងអំឡុងខែមិថុនា និងខែកក្កដារួមមានទាំងខែវិច្ឆិកាកាលពីឆ្នាំមុនផង។ ចាប់តាំងពីឆ្នាំ ១៩៦០ ដែលជាឆ្នាំមួយមានការរាំងស្ងួតជាងគេចំពោះទន្លេ ប្រសិនបើតាមរបាយការណ៍ខែកក្កដាបានបង្ហាញថា របាយទឹកភ្លៀងជាមធ្យមដែលទទួលបានពីការសិក្សាទាំង ១៦ កន្លែងគឺ មានកំពស់ ២៣១ ម.ម ដែលមានកំរិតទាបជាង ២៦១ ម.ម ដែលទទួលបាននៅក្នុងរយៈពេលដូចគ្នាក្នុងឆ្នាំ១៩៩២។ របាយទឹកភ្លៀងរវាងពីខែ កក្កដា ដល់ខែ តុលា បានបង្ហាញឱ្យដឹងនៅលំហូរជាមធ្យមនៃទឹកទន្លេមេគង្គជារៀងរាល់ឆ្នាំ ។ ដោយឡែកនៅក្នុងទីក្រុងភ្នំពេញ គេបានស្ទង់ឃើញលំហូរទឹកជាមធ្យមប្រចាំឆ្នាំគឺមានរហូតដល់ ៧៤ % សំរាប់រយៈពេល៤ខែ។ ផ្នែកដែលជាតំបន់លិចទឹកនៃអាងទន្លេមេគង្គគឺ ខ្ពង់រាបស្ថិតនៅផ្នែកខាងជើង និងខាងកើតនៃប្រទេសឡាវ "ប្រទេសឡាវផ្នែកខាងកើតនៃប្រទេសកម្ពុជា និងភាគកណ្តាលនៃប្រទេសវៀតណាម" ដែលមានរបាយទឹកភ្លៀងធ្លាក់ជាមធ្យមពី ២ ទៅ ៣ ម៉.ក្នុងមួយឆ្នាំ។ នៅក្នុងផ្នែកខ្លះនៃតំបន់អាងបន្ទាប់បន្សំដែលជាផ្នែកកណ្តាលនៃប្រទេសឡាវគឺ ជាអ្នកផ្តល់ទឹកទន្លេយ៉ាងធំជាងគេតែមួយគត់សំរាប់ទន្លេមេគង្គ ដែលគេគណនាឃើញរហូតដល់ទៅ ២០% ដែលបានបញ្ជោញទៅឱ្យជារៀងរាល់ឆ្នាំ។ ទន្លេ សេសាន នៃប្រទេសកម្ពុជា ជាតំបន់នៃអាងបន្ទាប់បន្សំធំជាងគេទី ២ (SeSan River) ហើយផ្នែកជាច្រើនទៀត ដែលមានទំនាក់ទំនងហូរចាក់ទៅទន្លេដែលស្ថិតនៅផ្នែកខាងកើតនៃប្រទេសកម្ពុជាចំណែកឯ ភាគកណ្តាលនៃទ្រទេសវៀតណាម និងផ្នែកខាងត្បូងនៃប្រទេស ឡាវ បានហូរចាក់ផ្តល់ទៅឱ្យប្រមាន១៦%។ លោក*កំបែល* បាននិយាយថា ការអង្កេតប្រចាំថ្ងៃនៅក្នុងខែមីនាឆ្នាំនេះបានបង្ហាញថា ទន្លេ

សៀង សៀន នៃប្រទេសថៃ (Chiang Saen River, Thailand) បានរងនៅឥទ្ធិពលតិចជាងភាគខាងត្បូងកំពង់ផែទន្លេប៉ាក់ សេ នៃប្រទេស ឡាវ (Port of Pakse, Laos)ដោយសារតែកំរិតហូរទឹកទាប ។ គាត់បានឱ្យដឹងថា " ប្រសិនកំរិតទឹកទន្លេមេគង្គហូរតិចដោយសារតែមូលហេតុមកពីការទប់ទឹកសំរាប់ផ្គត់ផ្គង់ទំនប់វារីអគ្គិសនី យើងសង្ឃឹមថា នឹងបានឃើញការហូរនៃទន្លេ សៀង សៀន មានឥទ្ធិពលខ្លាំងថែមទៀតជាងការហូរចុះទៅអាងទន្លេ ដែលជាកន្លែងហូរចូលមួយពីកន្លែងហូរចូលជាច្រើនទៅកាន់ទន្លេអាចធ្វើឱ្យប្រសើរឡើងចំពោះផលប៉ះពាល់ ។ គណៈកម្មការទន្លេមេគង្គបានវាស់វែងនៅកំពស់ទឹកទន្លេ សៀង សៀន និងទន្លេប៉ាក់ សេ ប្រចាំថ្ងៃជាច្រើនពាន់ដងដើម្បីធ្វើការប្រៀបធៀបទៅឆ្នាំ ១៩៦០ វិញ ។ គេបានរកឃើញថា នៅទន្លេ សៀង សៀន មានកំរិតទឹក ១២% ស្មើឬ ទាបជាងកំរិតទឹកទាបបំផុតដែលបានរាយការណ៍នៅក្នុងខែមិនាឆ្នាំនេះ ហើយទន្លេ ប៉ាក់ សេ វិញជាង ៤៤ ឆ្នាំកន្លងទៅនេះ គេបានវាស់ឃើញមានតែ ៥% គត់ដែលទាប ។

លោក *កំ វែបល* បានកត់សំគាល់ថា ទំនប់វារីអគ្គិសនីដែលមាននៅប្រទេសចិនធ្វើនៅលើទន្លេមេគង្គគឺ ក្នុងគោលបំណងដើម្បីទាញយកថាមពលអគ្គិសនីនឹងមិនមានបំនង ដើម្បីបង្វែរការបង្ហូរទឹកនោះទេ ។ ទំនប់វារីអគ្គិសនីដែលដើរដោយកំលាំងចរន្តទឹកហូរនេះនៅពេលដែលហូរ វាមិនធ្វើឱ្យមានការខុសប្លែកពីទន្លេធម្មជាតិទេ វាគ្រាន់តែជាសកម្មភាពឬដំណើរការទូទៅមួយសំរាប់ផ្ទុកទឹកដែលលើសនៅរដូវវស្សានិងសំរាប់ផ្គត់ផ្គង់ការបង្ហូរចេញខ្លះនៅរដូវប្រាំងដែលជារឿយៗនៅពេលដែលការហូរតាមលក្ខណៈធម្មជាតិវាមិនគ្រប់គ្រាន់សំរាប់តំរូវការធ្វើឱ្យឌីណាម៉ូវិល ។ គាត់បាននិយាយថា ផលប៉ះពាល់ដែលត្រូវបានគេគិតទុកជាមុនរបស់ទំនប់វារីអគ្គិសនី ម៉ាន វ៉ាន និង ដា ចៅសៀន (Man wan and Da chaoshan) នោះនឹងមិនធ្វើឱ្យរដូវប្រាំងហូរធ្លាក់ច្រើនជាងការធ្លាក់ចុះតាមធម្មជាតិរបស់វានោះទេ ។



*ភិតតី ស្តា ដែលជាអ្នកសរសេរអំពីសេដ្ឋកិច្ច និងជាអ្នកពិនិត្យមើលអំពី កាចេិញ្ចឹម និងការចាប់*





# ទិសដៅអភិវឌ្ឍន៍ដាយត្រីអាជីវកម្មរបស់ប្រជាជនកម្ពុជា៖ ជំនន់ និង សម្ពាធនៃការនេសាទ

លោក *កេនហ្គី ហតថល* (Kent G. Hortle)
លោក *ង៉ោ ប៉េងប៊ុន* (Ngor Pengbun)
លោក *ហែម រ៉ាឌី* និង (Hem Rady)
លោក *លាង សុផា* (Lieng Sopha)

**បើតាមរបាយការណ៍កាលពីដើមឆ្នាំនេះ ការចាប់ត្រីពីដាយនៅរដូវនេះបានចំនួន ៦.៥៥០ត. គឺចុះមកនៅត្រឹម ៤៧% ដែលជាចំនួនទាបបំផុតក្នុងប្រទេសកម្ពុជា។ បញ្ហានេះមួយផ្នែកបណ្ដាលមកពីកំរិតទឹកទាប ប៉ុន្តែឥឡូវនេះរយៈពេល ៣ ឆ្នាំជាបន្តបន្ទាប់កន្លងមក ផលត្រីចាប់បានបានធ្លាក់ចុះខ្លាំងដែលវាបណ្ដាលមកពីមានការកើនឡើងច្រើនការនេសាប។**

នៅក្នុងអំឡុងខែកក្កដារៀងរាល់ឆ្នាំទឹកទន្លេ សាប (TonleSap) បានហូរបញ្ច្រាស់ទិសនៅពេលដែលប្រព័ន្ធទឹកទន្លេមេគង្គហូរឡើងទៅចូលបឹងទន្លេសាប (Great Lake) តំបន់វាលទំនាបលិចទឹក និងតំបន់ដីសើម។ ទឹកជំនន់ទន្លេមេគង្គបាននាំយកទៅកូនត្រីតូចៗជាច្រើនលានដែលបានពងកូននៅដើមទឹកនៃទន្លេមេគង្គ និងហូរទៅចាក់តាមច្រកផ្លូវទឹកផ្សេងៗគ្រប់ទីកន្លែង។ កូនត្រីតូចៗ និងត្រីមួយចំនួនដែលបានពងកូននៅក្នុងតំបន់ទឹកលិចនោះបានស៊ីចំណី និងមានការរីកធំធាត់យ៉ាងខ្លាំងនឹងធំឡើងនៅទីនោះផងដែរ។ នៅខែ តុលា កំរិតទឹកបានចាប់ផ្ដើមធ្លាក់ចូលទៅក្នុងទន្លេសាប (Tonle Sap) ហើយបន្ទាប់មកចាប់ផ្ដើមហូរត្រឡប់ទៅកាន់ទន្លេមេគង្គ។ ដាយថាហេតុត្រី ត្រូវបានជំរុញឱ្យទៅតាមទឹកដែលហូរត្រឡប់ថយក្រោយធ្លាក់ចូលទៅប្រភពទឹកវិញ នឹងបន្ទាប់មកបានផ្លាស់ទីទាំងហ្វូងចូលទៅបឹងទន្លេសាប។ ហ្វូងត្រីជាច្រើនធ្វើដំណើរផ្លាស់ទីនៅក្នុងខែមករា និងកុម្ភៈ ដែលចំពេលមានសកម្មភាពនេសាទត្រីគ្រប់ប្រភេទកើតឡើងយ៉ាងច្រើនកុះករ។ ពេលនោះមានឧបករណ៍នេសាទប្រភេទធំៗដែលភាសាខ្មែរហៅថា (Dai) បានធ្វើការនេសាទយ៉ាងច្រើននៅតាមដងទន្លេសាប។ មានទីតាំងមួយកន្លែងត្រូវបានសង្ស័យថា មានការនេសាទដោយប្រើឧបករណ៍ដាក់ត្រងចរន្តទឹក ដែលមានលក្ខណៈស្រដៀងនឹងលូស្បៃម៉ុង (Trawl net)។ អ្នកសិក្សាស្រាវជ្រាវជាតិបារាំងបានកំណត់អាយុនៃការប្រើប្រាស់ឧបករណ៍របស់ពួកគេឱ្យត្រឡប់ទៅរកឆ្នាំ ១៨៨៤ វិញ។ មងនីមួយៗមានទទឹងប្រវែង ២៥ម៉. និងបណ្ដោយប្រវែង ១២០ ម៉. ដែលបន្ថែមតែ ២-៣ម៉.ទៀតនឹងក្លាយជាជ្រលងទន្លេ។ មងជាច្រើនគេបានដាក់តំរៀបជាជួរកាត់ទន្លេដែលមានចំនួន ៦៣ មង បានដាក់កាត់ទន្លេ ១៣ កន្លែងនៅរដូវនេសាទចុងក្រោយនេះ។ នៅក្នុងខែមករា និងកុម្ភៈគឺមានការចាប់យ៉ាងខ្លាំងនៅប្រភេទត្រីដែលសំខាន់ដូចជាត្រីរៀល (*Cirrhinussiamensis* and *C.lobatus.*) ហើយឡូត៍នេសាទនីមួយៗត្រូវដាក់ឱ្យដេញថ្លៃមានរយៈពេល ២ ឆ្នាំម្ដងដែលក្នុងមួយឆ្នាំៗរដ្ឋរកចំណូលបាន ១៨២.000 USD ពីការឱ្យសិទ្ធិធ្វើអាជីវកម្មនៅក្នុងដាយ។ អ្នកសិក្សាស្រាវជ្រាវជនជាតិបារាំង (Chevey and LePoulain,1940 )បានប៉ាន់ស្មានការចាប់ត្រីប្រហែលជា ១៣.៥៦៩តោន ក្នុងឆ្នាំ ១៩៣៨-៩ និងការប៉ាន់ស្មានផ្សេងៗទៀតដោផ្អែកទៅលើគំរូដែលគេបានធ្វើការសិក្សាក្រោយៗជាបន្តបន្ទាប់ដោយ លោក *ឡែន អេ អល* ក្នុងឆ្នាំ ១៩៩៥ (Lieng *et al.*, 1995)។ ចាប់តាំងពីឆ្នាំ ១៩៩៥-៦ ការឃ្លាំមើលយ៉ាងជិតដល់មួយត្រូវបានគេឧបត្ថមបន្តសំរាប់ស្រង់យកទិន្នន័យរយៈពេលវែងដែលបានអនុវត្តនៅក្នុងវិស័យជលផលនៃប្រទេសកម្ពុជា។ លោក *វេល ខាំ* នៅឆ្នាំ ១៩៨៥ (Welcomme,1985) បានកំណត់យ៉ាងច្បាស់ថា ទិន្នផលជលផលដែលបានមកពីទំនាបលិចទឹក




ក្រាប ១.

- ការចាប់សរុបនៃដាយអាជីវកម្មនេសាទត្រីនៃឆ្នាំនីមួយៗ(x១.០០០ត.)និងកំរិតកំពស់ទឹកដែលឡើងខ្លាំងនៅទន្លេសាប (**mASL**)។

- ទិន្នន័យពីកំពង់ផែភ្នំពេញដែលកំរិតទឹកមានទំនាក់ទំនងជាមួយ និងកំរិតទឹកនៅទន្លេសាបនិងបឹងទន្លេសាប



គឺដោយសារទឹកជំនន់។ នៅពេលមានទឹកជំនន់ធំគឺ វាបានបង្កើតទីជំរក ចំណីយ៉ាងសំបូរបែប នឹងធ្វើឱ្យកត្តាផ្សេងៗទៀតមានលំនឹងដូច្នេះផលិតផលត្រីកើនឡើងខ្ពស់ពេលនោះ។ ប្រសិនបើការធ្វើអាជីវកម្មនេសាទត្រីរួមផ្សំត្រីតូចៗដែលទើបបង្កកំណើតបានមួយឆ្នាំផងនោះ វានឹងមានផលអាក្រក់យ៉ាងខ្លាំងព្រោះនៅពេលនោះត្រីកំពុងមានទំនាក់ទំនងយ៉ាងប្រសើរជាមួយ និងកំពស់ទឹកជំនន់នៅក្នុងឆ្នាំនោះ។ ប៉ុន្តែការធ្វើអាជីវកម្មនេសាទតែត្រីធំៗវិញ វានឹងធ្វើឱ្យប៉ះពាល់ក្នុងរយៈពេលជាច្រើនឆ្នាំទៅលើកន្លែងចាប់ទោះបីមានទឹកជំនន់ខ្លាំងយ៉ាងណាក៏ដោយ។ នៅរវាងពីឆ្នាំ ១៩៩៥-៦ និងពីឆ្នាំ ២០០០-១ ការធ្វើអាជីវកម្មនេសាទត្រីតូចៗដែលទើបតែបង្កកំណើតនៅទន្លេសាបផលចាប់សរុបគឺ មានទំទាក់ទំនងជិតស្និទ្ធទៅវិញទៅមកលើកំពស់ទឹកជំនន់( ក្រាប១.)។ បន្ទាប់ពីមានការរាំងស្ងួតនៅឆ្នាំ ១៩៩៨ និងផ្អែកទៅលើទិន្នន័យមុនឆ្នាំ ១៩៩៨ គេបានសំគាល់ឃើញថា មានការចាប់ត្រីយ៉ាងខ្លាំងប៉ុន្តែការស្នើរសុំកែរឱ្យមានភាពដូចដើមនៅចំនុចដែលអវិជ្ជមានខ្លះនោះ វាប្រហែលជាមិនឈានទៅដល់កំរិតមួយដែលត្រូវបានគេគិតទុកជាមុននោះទេ។ ក្រោយឆ្នាំ ២០០១-២ ផលចាប់មានកំរិតកាន់តែទាបទៅៗដែលបណ្តាលមកពីកំរិតទឹកជំនន់តែមួយគត់ ។ តាមការរាយការណ៍នៅក្នុងឆ្នាំ ២០០៣ - ៤ ផលត្រីមានកំរិតទាបបំផុត និងកាន់តែទាបជាងនេះទៅទៀតគឺ បញ្ហានេះបណ្តាលមកពីទឹកជំនន់តែមួយគត់។ ពេលវេលានិងរយៈពេលនៃទឹកជំនន់គឺជាកត្តាសំខាន់ដែលបានជះឥទ្ធិពលលើផលចាប់។

*ថ្មីៗនេះតើទឹកជំនន់ឡើងឆាប់ ឬយឺតជាងធម្មតា ?* ទឹកជំនន់ឡើងយ៉ាងខ្លាំងនៅក្នុងទន្លេសាប រួចបានហូរទៅចាក់គ្រប់ច្រកល្ហកជារៀងរាល់ឆ្នាំ។ នៅចន្លោះរវាងឆ្នាំ ១៩៩៥ និងឆ្នាំ ២០០៣ ទឹកឡើងខ្លាំងលឿនបំផុតគឺ នៅថ្ងៃទី ១៨ ខែ កញ្ញា ក្នុងឆ្នាំ ១៩៩៥ និងយឺតបំផុតគឺ នៅថ្ងៃទី ៤ ខែ តុលា ឆ្នាំ ១៩៩៩ គេអាចដឹងទឹកជំនន់មុនបានក្នុងរយៈពេលតែពីរអាទិត្យហើយវាក៏មានទំទាក់ទំនងទៅនឹងពេលវេលាផងដែរ។ ការប្រែប្រួលកំពស់ទឹកជំនន់ប្រចាំឆ្នាំបើប្រៀបធៀបទៅនឹងទន្លេដែលមាននៅតំបន់ត្រូពិចដទៃទៀតគឺ វាមានកំរិតតិចតួច ( *តាមឯកសាររបស់គណៈកម្មការទន្លេមេគង្គ ២០០៣* )។ តើវាអាចបណ្តាលមកពីភាពខុសប្លែកគ្នានៃរយៈពេលជំនន់ ឬក៏មកពីមានការបកស្រាយផលចាប់ទាប? ប្រសិនបើតាមក្រាបទី ២ បានបង្ហាញថា មកពីមានកំពស់ទឹកជំនន់តូច និងមានរយៈពេលខ្លីនៅក្នុងឆ្នាំ ២០០៣។ ប៉ុន្តែជារួមទោះបីជាមានជំនន់រយៈពេលខ្លី និងតូចយ៉ាងណាក៏ដោយក៏គ្មានអ្នកនេសាទណាមួយយល់អំពីផលចាប់ដែលមានការធ្លាក់ចុះក្នុងរយៈពេលពី២-៣ឆ្នាំមុននោះដែរ។ សព្វថ្ងៃនេះសម្ពាធនៃការ

នេសាទមានការកើនឡើងជាបន្តបន្ទាប់នៅតាមដងទន្លេសាប និងបឹងទន្លេសាប ។ ជារៀងរាល់ឆ្នាំអ្នកនេសាទ និងឧបករណ៍នេសាទកើនកាន់ច្រើនឡើងទាំងខុស និងស្របច្បាប់ ។ បច្ចុប្បន្ននេះមានអ្នកនេសាទជាលក្ខណៈគ្រួសារចំនួនមួយម៉ឺននាក់បានប្រើមងនីឡុងក្រឡាល្អិតធ្វើនេសាទនៅរដូវត្រីត្រូវ ។ បើតាមការឃ្លាំមើលការសិក្សាស្រាវជ្រាវកាលពីដើមឆ្នាំនេះទៅលើត្រីជាច្រើនដែលគេបានដាក់ផ្លាកសំគាល់ និងបានព្រលែងទៅពីដាយនៅចុងទឹកគឺ មានតែប្រើមងទេទំនងជាអាចចាប់ត្រីបានច្រើននិងដោយងាយស្រួលដែលដាយមិនអាចចាប់ត្រីបានច្រើននោះ។ នឹងមានការចាប់ត្រីតាមបែបផ្សេងជាច្រើនទៀតដែលការចាប់នោះរួមមានទាំងការនេសាទលើសលប់ទាំងត្រីប្រភេទធំៗ និងមធ្យមនៃត្រីសំខាន់តូចៗដែលកំពុងមិនត្រឹមតែចាប់បានដោយដាយទេ ថែមទាំងត្រូវបានគេកំពុងតែចាប់បានដោយ ឧបករណ៍ខុសច្បាប់ដទៃទៀតដែលមិនមែនជាប្រភេទឧបករណ៍នេសាទផងដែរ ដែលឥឡូវនេះផលចាប់សរុបមានការធ្លាក់ចុះ។ សរុបសេចក្តីមក ជាទូទៅផលចាប់បានធ្លាក់ចុះ នៅក្នុងឆ្នាំថ្មីៗនេះការចាប់ត្រីពីដាយបានផលបន្តិចបន្តួចគឺ យ៉ាងហោចណាស់មានមួយផ្នែកដែលគេបានបកស្រាយថា អាចបណ្តាលមកពីមានការនេសាទយ៉ាងធ្ងន់ធ្ងរ ។ ជាធម្មតា ត្រីខ្លះទៀតមិនត្រឹមតែចាប់បានដោយដាយទេថែមទាំងត្រូវបានគេកំពុងតែចាប់បានដោយ ឧបករណ៍ខុសច្បាប់ដទៃទៀតដែលមិនមែនជាប្រភេទឧបករណ៍នេសាទផងដែរ ដែលឥឡូវនេះផលចាប់សរុបមានការធ្លាក់ចុះ។ ជាទូទៅការធ្លាក់ចុះផលចាប់សរុបគឺ វាបណ្តាលមកពីមានការនេសាទដ៏ច្រើនលើសលប់ដែលគេបានកំណត់កំរិតការចាប់ឱ្យស្ថិតក្រោមភាពមួយដ៏ប្រសើរបំផុតដែលអាចឱ្យវាគង់វង្សបាន ។ជាធម្មតាអ្នកវិទ្យាសាស្រ្តជាច្រើនមានការស្ទាក់ស្ទើរក្នុងការអះអាងទៅលើឧបហេតុដែលកើតឡើងណាមួយដោយគ្មានភស្តុតាងពិតប្រាកដនោះទេ។ ប៉ុន្តែជាទូទៅកង្វះខាតការពិតនៅក្នុងវិទ្យាសាស្រ្តជលផលក៏ដូចជានៅក្នុងវិទ្យាសាស្រ្តបរិស្ថានដែរគឺ វាមិនមែនមកពីគ្មានការពិតនោះទេ (see Downes *etal*, 2002) ។ យើងទាំងអស់គ្នាមិនត្រូវរងចាំមើលរហូតដល់ជលផលវិនាសអន្តរាយទើបយើងនាំគ្នាចាត់វិធានការគ្រប់គ្រងឱ្យមានប្រសិទ្ធិភាពនោះទេ ។




ក្រាប ២.

- កំរិតទឹកទន្លេសាបប្រចាំថ្ងៃពីឆ្នាំ ១៩៩៥ ដល់ ឆ្នាំ ២០០៣
- ទិន្នន័យពីកំពង់ផែភ្នំពេញដែលកំរិតទឹកមានទំនាក់ទំនងជាមួយនិងកំរិតទឹកនៅទន្លេសាប និងបឹងទន្លេសាប



## ការទទួលស្គាល់

លទ្ធផលទិន្នន័យដែលយកបានពីដាយត្រីជាច្រើនដោយការខិតខំប្រឹងប្រែងរបស់អ្នកប្រមូលទិន្នន័យជាច្រើននាក់ដូចជាលោកបណ្ឌិត *និកវ៉ាន់ ហ្សាលិង* (Dr Nikvan Zalinge) និងអតីតៈសមភាគីនាយកដ្ឋានជលផលនៃកម្មវិធីជលផល របស់គណៈកម្មការទន្លេមេគង្គ និងរួមមានទាំង

លោក *ឌៀប ឡឹង* (Deap Loueng)

លោក *យឹម ជា* (Yim Chea)

លោក *ហេង កុង* ( Heng Kong)

លោក *ជួន ចំណាន* និង ( Chhoun Chamnan)

លោក *សឿន សុទ្ធា* (Souen Sotthia)

និងទិន្នន័យជលវិទ្យាត្រូវបានផ្តល់ដោយលោកបណ្ឌិត ឆៃយ៉ា-និស ម៉ានូសធីរាប៉ម (Chayanis Manusthirapom) ដែលជាអ្នកជលវិទូនៃលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ ។

## ឯកសារយោង

Chevey, P. and Le Poulain, F. 1940. La peche dans les eaux douces du Cambodge. Travaux de l'Institut Oceanographique de l'Indochine. 5e Memoire. Gouvernement Generale de l'Indochine.
Saigon. 241 pp.

Downes, B. J., Barmuta, L. A., Fairweather, P. G., Faith,
D. P., Keough, M. J., Lake, P. S., Mapstone, B. D., and
Quinn, G. P. 2002. Monitoring Ecological Impacts:
Concepts and Practice in Flowing Waters. Cambridge
University Press, Cambridge, UK.

Lieng, S., Yim, C., and van Zalinge, N. P. 1995.
Freshwater fisheries of Cambodia, I: The bagnet (dai)
fishery in the Tonle Sap River. Asian Fisheries Science
8: 255-262.

MRC. 2003. State of the Basin Report. Mekong River
Commission. Phnom Penh. 300 pp.

Welcomme, R. L. 1985. River Fisheries. FAO Fisheries Technical Paper 262: Food and Agricultural
Organisation of the United Nations, Rome. 330 pp.











# ការជ្រើសរើសសំណាកកូនត្រី

ដោយលោក *កេនយី ហតធល* (Kent G. Hortle)

**មានអ្នកជីវសាស្ត្រជាច្រើនបានស្គាល់ច្បាស់សំណាកត្រីជំទើ និងពេញលក្ខណៈ។ ប៉ុន្តែថ្មីៗនេះ គ្រាន់តែជាការប៉ុនប៉ងដែលបានធ្វើទៅលើសំណាកត្រីជំទើ និងពេញលក្ខណៈគឺមាននៅតែក្នុងទន្លេធំៗជាច្រើននៃតំបន់ត្រូពិកប៉ុណ្ណោះ។ ខ្នាតសំណាញ់គំរូកំពុងតែត្រូវបានគេប្រើពេលនេះគណៈកម្មការទន្លេមេគង្គកំពុងតែមានគោលបំណងពង្រីកការយកសំណាកកូនត្រីដែលឆ្លងកាត់អាង ។**

ទន្លេដែលនៅក្នុងតំបន់ត្រូពិក មានប្រភេទពូជត្រីជាច្រើនដែលពងនៅដើមទឹកនៃតំបន់ទំនាបលិចទឹកសំខាន់ៗដែលមានកំរិតទឹកខ្ពស់។ ពងត្រី ត្រីជំទើ និងពេញលក្ខណៈបានហូរសាត់អណ្តែតទៅចុងទឹកដែលជាអ្នកនាំវាបាចសាចទៅកាន់តំបន់ជាច្រើន។ នៅក្នុងប្រព័ន្ធទន្លេមេគង្គទឹកជំនន់ជាអ្នកបង្កើតពងដែលរួមមានទាំងពពួកត្រីអត់ស្រកាសំខាន់ៗជាច្រើន (panga-siids) និងត្រីកាបទន្លេ (cyprinids) ។ មងអាចត្រូវបានគេប្រើដើម្បីចាប់ពពួកត្រីជំទើ និងពេញលក្ខណៈទាំងនេះដែលកំពុងហូរសាត់អណ្តែតជាមួយនឹងសរីរៈផ្សេងៗដទៃទៀត ដូចជាពពួកវារីសត្វល្អិត និងរួមមានទាំងពពួកដែលតោងនៅលើកូនត្រី និងបង្គា។ ការចាកចោលទីកន្លែងនៃកូនត្រីតូចៗធ្វើឱ្យពួកគេងាយស្រួលក្នុងការចាប់ជាងត្រីធំៗ និងមានតម្លៃថោក ។ ការមើលទៅលើសំណាកអាចឱ្យយើងដឹងនៅប្រភេទត្រីផ្សេងៗ និងសមាសភាព ពេលវេលាបង្កាត់ពូជ និងទីជំរកពងកូនផងដែរ។ សំណាកអាចឱ្យយើងដឹងផងដែរនៅសមត្ថភាពរបស់ត្រីសំរាប់ចិញ្ចឹមពិសោធន៏នៅក្នុងវារីវប្បកម្ម។ ជាទូទៅវាបានឱ្យយើងដឹងថែមទៀតនៅជាតិពុល ហើយវាអាចផ្តល់ឱ្យយើងដឹងនៅគុនភាពទឹក និងទីជំរក។ វត្តមានពពួកកូនត្រីបានបង្ហាញថា វាមានការប្រែប្រួលគ្រប់ដំណាក់កាលរហូតដល់ធំបង្កាត់ពូជ។ វាអាចចាប់បានដោយឧបករណ៏ដូចជាអ្នកនេសាទប្រើ ចរន្តអគ្គិសនី ទ្រូតូចៗ មងបណ្តែត អ្នកយកសំណាកទឹកស៊ីប អួន សៃយឺន មងហ៊ុំ មងរូត មងភ្លោះ និងប្រើជាតិគីមីពុលជាដើម។ វិធីសាស្ត្រដែលយកមកប្រើវាអាស្រ័យលើ គោលបំណងនៃការសិក្សា ប្រភេទពូជត្រី ដំណាក់កាលនៃការវិវឌ្ឍន៍ និងប្រភេពនៃទីជំរក ។





សំណាកកូនត្រីចាប់ដោយកន្ទ្រកស្បៃមុងពីទន្លេមេគង្គនៅក្បែរទីក្រុងភ្នំពេញ ។ គេបានដាក់កន្ទ្រកស្បៃមុងជាពីរផ្នែកគឺ នៅជិតផ្ទៃលើ និងនៅជិតបាតក្រោមនៃទន្លេ

Bongo nets ត្រូវបានគេយកមកប្រើនៅក្នុងការសិក្សាជាច្រើន។ ជាធម្មតាគេប្រើវាសំរាប់យកគំរូសំណាកធារាសុខុមប្រាណដែលមានអង្កត់ផ្ចិតប្រវែងពី ៣០ ស.ម ទៅ ១ម៉. និងមានទំហំក្រឡាពី ០.៥ ម.ម ទៅ ១ ម.ម។ ការវាយតម្លៃសមាសភាពចាប់នៃផលផលទន្លេមេគង្គរបស់កម្មវិធីជលផលនៃលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ គោលបំណងគឺដើម្បីបង្កើនការយកសំណាកកូនត្រីនៅអាងឱ្យបានច្រើន ។ បញ្ហានេះនឹងត្រូវផ្អែកទៅលើសំណាញ់ដែលគេបានកំណត់ទំហំដែលមានអង្កត់ផ្ចិត ៤០ ស.ម.ឬ ១ម៉ និងទំហំក្រឡា ១ម.ម. ។សំរាប់មងដែលបានលើកឡើងខាងលើ វាមានលក្ខណៈងាយស្រួលសំរាប់ទុកដាក់ សំរាប់នេសាទ និងមានតម្លៃថោកល្មម។ ដោយផ្អែកទៅលើទិន្នន័យដង់ស៊ីតេកូនត្រីដែលមាន វាអាចទ្រទ្រង់កំលាំងទឹកគ្រប់គ្រាន់សំរាប់បរិមានកូនត្រីដ៏ច្រើនដែលគេទទួលបាននៅរដូវពងកូន។ ទំហំក្រឡា ១ម.ម.គឺ ធំល្មមគ្រប់គ្រាន់ដើម្បីទុកឱ្យសំរាមឬកំទេចកំទីចេញម្តងមួយៗដោយមិនចាំបាច់ធ្វើឱ្យមានការកកស្ទះនៅខាងក្នុង ។វាក៏មានលក្ខណៈល្អសំរាប់ចាប់កូនត្រីពូជតូចៗបានយ៉ាងច្រើនផងដែរ។ ជា ឧ.ហ. កូនត្រីកាបទន្លេតូចៗ និងពួកត្រីអត់ស្រកាជាដំបូងបានរលាយជាតិពណ៌នៃស៊ុតបន្ទាប់មកចាប់ផ្តើមស៊ីចំណីគឺ នៅចន្លោះរវាងបណ្តោយពី ៤-៨ ម.ម.។ ប៉ុន្តែចំពោះកូនត្រីពូជប្រភេទផ្សេងវិញមុនទំហំនេះមិនអាចកំណត់បានទេ ។ចំណែកមួយដែលបានមកពីការប្រែប្រួលរដូវកាលគឺ ដង់ស៊ីតេកូនត្រីតូចៗទាំងនេះវិវត្តន៍មុនថ្ងៃ ហើយវាបានទៅរកកន្លែងដែលសំខាន់នៃទន្លេដោយឆ្លងកាត់នៅដំណាក់កាលដូចជា ដំណាក់កាលនៅផ្ទៃទឹកខាងលើ ឬ ក៏ដំណាក់កាលបង្កាត់ពូជ ឬ ក៏ដំណាក់កាលដំណើរស្វែងរកចំណី ឬ ដំណាក់កាលចូលទៅរកកន្លែងពងកូន។ ផ្នែកទាំងអស់នេះត្រូវធ្វើការសិក្សា និងមានមាត្រដ្ឋានវិធីសាស្រ្តត្រឹមត្រូវមុនពេលការយកសំណាកដែលមានទំហំធំត្រូវបានគេអនុវត្តន៍ ដូច្នេះភាពខុសគ្នា នឹងត្រូវបានគេរកឃើញទីកន្លែង និងរយៈពេលដែលមិនមែនជាការយកសំណាកបែបបុរាណ

ធម្មតានោះទេ។ ការយកសំណាកនេះ ដោយមានការវាយតម្លៃទៅលើសមាសភាពចាប់នៃជលផលសំដៅលើប្រភេទពូជត្រីដែលមានពងរសាត់អណ្តែតនៅក្នុងទន្លេ។ ផ្ទុយទៅវិញការយកសំណាកប្រភេទពូជកូនត្រីខ្លះដែលពងកូននៅទន្លេដែរនោះមិនអាចស្រង់យកបានដោយមងរាយបណ្តែតទេពីព្រោះ ពួកគេបានប្រមូលផ្តុំលូតលាស់នៅតាមខាងៗមាត់ទន្លេ និងកន្លែងដែលសាំញ៉ាំ។ នឹងវិធីសាស្ត្រផ្សេងទៀតត្រូវតំរូវទៅតាមប្រភេទត្រីដែលពងកូននៅតំបន់ទំនាបលិចទឹកដែលប្រភេទត្រីទាំងនោះមេបាជាអ្នកចាំយាមពង ឬចាំការពារកូនដែលទើបនឹងញាស់។ ថ្មីៗនេះផ្នែកការវាយតម្លៃសមាសភាពចាប់នៃជលផលបានកំពុងរៀបចំធ្វើការបង្ហាញវិធីសាស្ត្រលំអិតសំរាប់ការយកសំណាកកូនត្រី ។ព័ត៌មានពីស្ពានជាងនេះទៀតអាចរកបានពីអ្នកចងក្រងអត្ថបទនេះ ។លោក *កេន ហកថល* (Kent Hortle) ជាអ្នកជីវសាស្ត្រជលផលដែលកំពុងតែធ្វើការឱ្យកម្មវិធីជលផលនៃលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ ។ ប្រសិនបើមានករណីចាំបាច់សូមទាក់ទងទៅកាន់តាមរយៈសំបុត្រអេឡិចត្រូនិចនេះ: hortle@mrcmekong.org ។







# សារៈសំខាន់ព្រុយរបស់ត្រី

ដោយលោក *ចនវ៉ល ប៊ូយ៉ូយែនសេន* (John Valbo Jorgensen) និងលោក *កេនឃី ហកធល* (Kent G. Hortle)

**ព្រុយត្រីមានតួនាទីយ៉ាងសំខាន់សំរាប់ហែលទឹក។ ប៉ុន្តែវាមានតួនាទីប្រើក្នុងគោលបំណងសំរាប់ការពារខ្លួនឯង ដែនទឹក ស្តែងចេញសកម្មភាពចាប់គូរដើម្បីបង្កាត់ពូជរបស់វា និងអែបពិតទៅនឹងថ្មនៅពេលដែលវាកំពុងហែលឆ្វាត់ឆ្វែង។**

ព្រុយត្រីសំរាប់សំគាល់លក្ខណៈខាងក្រៅនៃត្រីនីមួយៗ ហើយក៏ប្រហែលជាសំរាប់សំគាល់លក្ខណៈជាច្រើនផ្សេងៗទៀត ។ ព្រុយនីមួយៗមានរាងរៅលក្ខណៈខុសៗគ្នាតាមប្រភេទពូជនីមួយៗ ប៉ុន្តែវាមានទ្រង់ទ្រាយសាមញ្ញដូចគ្នា ។ព្រុយពោះ( ទ្រូង) មួយគូរនិងព្រុយគុម្ពកន្ទុយ( ត្រកៀក) មួយ វាមានទំនាក់ទំនងទៅនឹងព្រុយចំហៀងទាំងសងខាងហើយនឹងព្រុយទ្រនុងលើ ។ ត្រីនីមួយៗមានរន្ធគូទមួយ កន្ទុយ ព្រុយខ្នង។ ព្រុយនីមួយៗមានលក្ខណៈស្តើងៗស្រួចហើយជាទូទៅវាអាចធ្វើចលនាបាន និងស្ថិតនៅតំរៀបជាជួរ និងភ្ជាប់ដោយភ្នាសស្បែកស្តើងទន់។ សាច់ដុំមានមុខងារពិសេសប្រើសំរាប់បង្កើតឱ្យមានចលនាឬក៏បទបែនព្រុយ ប៉ុន្តែសណ្តានព្រុយពោះប្រើសំរាប់ត្រួតពិនិត្យចលនាតំរង់ទិស ។ ព្រុយទ្រនុងមិនទាំងទុនទេថែមទាំងមានបន្លាផងដែរ ។ព្រុយទ្រនុងដែលទន់អាចស្ថិតនៅត្រង់ចំណុចចុងនៃព្រុយទ្រនុងរបស់វា។ ព្រុយទ្រនុងដែលមានបន្លាអាចមាននៅលើព្រុយទ្រនុងជាច្រើនគឺ លើកលែងតែព្រុយគុម្ពកន្ទុយ ។ ទោះបីយ៉ាងណាក៏ដោយ ត្រីធម្មតាភាគច្រើនមានបន្លានៅលើទ្រនុងខ្នងរបស់វា។ ប៉ុន្តែប្រសិនបើប្រភេទពូជដែលមានព្រុយទ្រនុងខ្នងពីរជារើយៗវាគឺមានតែព្រុយទ្រនុងមុខទេដែលមានបន្លា ។ព្រុយត្រីឆ្លាមគឺ វាមានលក្ខណៈរឹងមាំ មិនមានខ្នែង និងមិនមានទ្រនុងឆ្អឹងខ្ចីដាច់ពីគ្នាទេ។ ប៉ុន្តែព្រុយត្រីឆ្លាមខ្លះមានបន្លានៅជាប់នឹងព្រុយទ្រនុងខ្នងទីមួយរបស់វា ( ព្រុយត្រីឆ្លាមទន្លេមេគង្គមិនមានបន្លាទេ) ។ព្រុយទ្រនុងខ្នងនៃប្រភេទត្រីខ្លះដូចជា sheatfishes (Siluridae) នៅសល់តិចបំផុត ឬ ស្ទើរតែគ្មាន ។និងប្រភេទផ្សេងដទៃទៀតព្រុយទ្រនុងខ្នងចែកចេញជា ២ ឬ ៣ប្រភេទ។ មានប្រភេទត្រីខ្លះដូចជាពពួកត្រីអត់ស្រកា (Siluriformes) ព្រុយដែលមានជាតិខ្លាញ់ច្រើនគឺព្រុយតូចនីមួយៗសំបូរទៅដោយជាតិខ្លាញ់ដែលមានសន្ដានដូចជាខ្នែង និងគ្មានទ្រនុងរវាងចន្លោះព្រុយគុម្ពកន្ទុយ និងព្រុយខ្នង ។ ជួរនៃព្រុយរបស់វាមិនសូវជាពេញលក្ខណៈទេ ប៉ុន្តែវាដើរតួជាអ្នកជួយសំរាលក្នុងការប៉ះទង្គិចនៅពេលដែលធ្វើសកម្មភាព។ ព្រុយគុម្ពកន្ទុយមិនទាំងតភ្ជាប់គ្នាជាមួយនឹងព្រុយទ្រនុងខ្នងទេថែមទាំងតភ្ជាប់ជាមួយព្រុយរន្ធបន្តពូជដូចជាពពួក ត្រីអន្ទុងដែលមានបន្លាច្រើន (Mastacembelidae) ត្រីអណ្តាតឆ្កែសមុទ្រធំៗ (Soleidae) និងត្រីអណ្តាតឆ្កែ (Cynoglossidae)។ ជាធម្មតាព្រុយរបស់វាប្រើជាកំលាំង និងធ្វើឱ្យមានលំនឹងនៅពេលហែល និងសំរាប់ធ្វើជាល្បិចកល។ វាធ្វើចលនាឆ្ពោះទៅមុខដោយកន្ត្រាក់សាច់ដុំតាមបណ្តោយឆ្អឹងខ្នងរបស់វាបង្កើតជាចលនារលកចាប់ពីក្បាលរហូតដល់កន្ទុយរបស់វា និងដោយចលនាបទបែនព្រុយកន្ទុយរបស់វា។ ចំពោះប្រភេទត្រីធូណា (tunas) វិញមានចលនាបទបែនលឿនគឺដោយសារការបញ្ចេញថាមពលសាច់ដុំយ៉ាងខ្លាំងរបស់វាជាមួយនឹងព្រុយកន្ទុយវែងហើយធំដើម្បីទាញកន្ត្រាក់ធ្វើឱ្យដងខ្លួនបទបែនយ៉ាងរហ័ស។ ត្រីដែលមានចលនាយឺតៗដោយសារតែវាប្រើតែសាច់ដុំកន្ត្រាក់ដងខ្លួនដើម្បីចលនាទៅមុខ។




ពពួកប្រភេទទាំងនេះគឺ វាមានព្រុយកន្ទុយតិចតួច ឬ ក៏គ្មាន ប៉ុន្តែមានភាគច្រើនដូចជាត្រីច្លុកវាមានចលនាយ៉ាងខ្លាំង (Anguillidae) ។ ត្រីបានប្រើព្រុយសំខាន់ៗផ្សេងដទៃទៀតដើម្បីតំរង់ទិស ឬ កាច់ចង្កូត និងដើម្បីរក្សាលំនឹងដងខ្លួនរបស់វានៅក្នុងទឹក ។ ទោះបីយ៉ាងណាក៏ដោយត្រីចៃក្រពើ (Syngnathidae) និងត្រីក្រាយ (Notopteridae) ហែលដោយសារព្រុយរន្ធបន្តពូជ និងព្រុយខ្នងទោលរបស់វា ។ត្រីកង្កែប frogfishes (Batrach-oididae)ធ្វើចលនាបានដោយសារព្រុយដែលមាននៅផ្នែកខាងក្រោមរបស់វា ។ ព្រុយត្រីមានមុខងារយ៉ាងច្រើនផ្សេងទៀតដូចជាប្រើសំរាប់ការពារដែនជំរក ឬ សំរាប់ធ្វើជាសញ្ញាទាក់ទាញពេលបង្កាត់ពូជ ។ឧទាហរណ៍ ត្រីក្រឹមភ្ញើកញី fighting fish (*Betta s-plendens*) ប្រើព្រុយរន្ធបន្តពូជ កន្ទុយ និងខ្នង ដែលមានពណ៌ភ្លឺថ្លា និងយ៉ាងធំរបស់វាសំរាប់ប្រមានទៅដល់ត្រីញីដទៃទៀតដើម្បីការពារទីជំរករបស់វា ។ ចំពោះបន្លាព្រុយគឺ ជាសមាសភាពសំខាន់មួយដែលត្រីភាគច្រើនប្រើធ្វើជាប្រព័ន្ធការពារ ។ មានត្រីជាច្រើនប្រភេទដែលមានព្រុយ ខ្នង រន្ធបន្តពូជ និងព្រុយបន្លាពោះ ដែលមានលក្ខណៈ រឹង មុត ធ្វើឱ្យសត្រូវរួញរា ។ ទំហំនៃព្រុយបន្លាដែលមាននៅលើខ្លួនវាបានរីកធំឡើងប្រកបដោយឥទ្ធិពលនៅពេលដែលវាការពារកន្លែងរបស់វាដែលជាការលំបាកមួយសំរាប់ការលេបរបស់សត្រូវ ។ ជាងនេះទៅទៀតព្រុយបន្លានៃត្រីប្រភេទខ្លះដូចជាត្រីគ្មានស្រកា catfishes (Ariidae) គឺ សំរាប់ការពារជាតិគីមីពុល ។ ព្រុយសរសៃនៃត្រី *ព្រាម ស* (Polynemidae) ប្រើសំរាប់ទ្រង់ញ្ញាន្ត និងសរសៃព្រុយឆ្មារៗយ៉ាងវែងដែលមាននៅលើពោះរបស់វា សំរាប់ចាប់យកសត្វគ្មានឆ្អឹងខ្នងដែលកប់ទៅនឹងដុំថ្មបានយ៉ាងងាយស្រួល ។



ត្រី ក្អុក *Anidae*



ត្រី ព្រាម ស *Polynemidae*



FAO Name:
Dog-toothed goby *Gobiidae*



ត្រី ក្រាយ *Notopteridae*



FAO Name: *Batrachoididae*
Banded toadfish



ត្រី ក្រឹមភ្លើក *Betta splendens*



ត្រី កាបូ ឬ ចៃក្រពើ *Syngnathidae*

នៅក្នុងជំរៅភក់។ ដោយឡែកត្រី Dog-toothed goby (Gobiidae) ភាគច្រើនមានព្រុយគុម្ពកន្ទុយរលាយចូលគ្នា ដែលដុះចេញមកជាពន្លកខ្នែងដែលអាចធ្វើឱ្យពួកវាតោងជាប់ ប្រហែលជាមានភាគច្រើនជាត្រីសមុទ្រដូចជា (Exocoetida-e)ដែលមានព្រុយពោះសំរាប់លោតឡើង ដែលព្រុយនេះអាចរីកធំឡើងដើម្បីធ្វើឱ្យវាអាចហោះសំកាំងបានយ៉ាងយូរនៅក្នុងអាកាស។ ព្រុយត្រីដែលមានមុខងារជាច្រើន និងមានលក្ខណៈខុសប្លែកៗគ្នារវាងប្រភេទពូជនីមួយៗគឺ ព្រុយត្រីទាំងនោះមានលក្ខណៈពិសេសសំខាន់របស់វាគឺ សំរាប់ប្រើដើម្បីសំគាល់ត្រីនីមួយៗ។ លក្ខណៈព្រុយសំខាន់ៗរួមមានទាំង ទីតាំង និងចំនួនដែលមានទំនាក់ទំនងគ្នារបស់វា ចំនួននៃទ្រនុងព្រុយបន្លាតិច ឬ ច្រើន នឹងទោះបីជាបន្លារលីង ឬ ស្រួចក៏ដោយ។

# ការបរិភោគត្រីដែលបណ្តាលឱ្យស្លាប់នៅក្នុងពិធីបុណ្យ

ដោយលោកបណ្ឌិត គ្រិស្ត បាឡូ ( Chris Barlow )

ក្នុងខណៈដែលទន្លេមេគង្គមានត្រីប្លែកៗសំរាប់ហូបយ៉ាងច្រើន ត្រីមួយប្រភេទដែលគ្រោះថ្នាក់គឺ មិនគួរត្រូវគេដាក់បញ្ចូលទៅក្នុងបញ្ជីរាយនាមឈ្មោះត្រីទេ ។ នៅក្នុងខែសីហា មានបុរសពីរនាក់រស់នៅទិសពាយព្យនៃប្រទេសកម្ពុជាបានរងគ្រោះរហូតដល់ស្លាប់ដោយសារហូបត្រីដែលមានជាតិពុលត្រូវបានគេលើកយកមកនិយាយនៅពេលនេះ ។ត្រីដ៏គ្រោះថ្នាក់នេះគឺជាត្រីមួយប្រភេទយ៉ាងសាមញ្ញសំបូរនៅក្នុងទន្លេមេគង្គ ។ត្រីនេះត្រូវបានគេដាក់ឈ្មោះឱ្យដោយសារតែវាមានសមត្ថភាពធ្វើឱ្យខ្លួនរបស់វាឡើងប៉ោងបានដែលមានសណ្ឋានដូចបាល់ ។ វាធ្វើឱ្យឡើងប៉ោងបានដោយសារតែក្រពះអាហាររបស់វាជាមួយនឹងទឹក ឬខ្យល់ដើម្បីការពារទប់ទល់ជាមួយសត្រូវ ឬក៏មនុស្សក្រោយពីវាត្រូវបានគេកំពុងចាប់ ។ វាត្រូវគេស្គាល់ជាភាសា វៀតណាមថា ត្រីកា ណុក (ca noc) ជាភាសាខ្មែរត្រី កំពត (trey kampot) និងភាសា ឡាវ និង ថៃ ត្រីប៉ាវ (pa pao) វាគឺ ជាត្រីមិនមានតម្លៃខាងសេដ្ឋកិច្ចទេ ប៉ុន្តែ ជារឿយៗវាត្រូវបានជាប់មង និងទ្រូរបស់អ្នកនេសាទ ដែលគោលបំណងរបស់គេគឺ ត្រីប្រភេទផ្សេងៗ ។ សាច់វាមិនមានជាតិពុលទេ ប៉ុន្តែសរីរាង្គ និងស្បែករបស់វាមានជាតិពុលច្រើន ។ ជាតិពុលនេះ (tetrodotoxin) មិនបានបង្កើតឡើងដោយខ្លួនវាផ្ទាល់ទេ ប៉ុន្តែដោយសារមេរោគ (bacteria) នៅខាងក្រៅជុំវិញវា ។ សារធាតុពុលគឺមានច្រើនជាង ១.២០០ ដងនៃជាតិពុល cyanide ដែលបណ្តាលឱ្យស្លាប់បាន ហើយជាតិពុលមិនមានគ្រប់គ្រាន់ក្នុងខ្លួនវាសំរាប់ឱ្យមនុស្សពេញវ័យអាយុ ៣០ ឆ្នាំស្លាប់នោះទេ ។ ជាធម្មតាក្នុងរយៈពេលពី ២០ នាទីទៅ ៣ ម៉ោងការពុលមុនគេគឺ បបូរមាត់ និងមាត់ ។ ការប្រែប្រួលអារម្មណ៍ដឹងថាក្តៅយ៉ាងលឿននេះគឺ កើតមាននៅលើមុខ និងអវៈយវៈដៃជើង ។ ជាធម្មតាភាពដែលមិនអាចកំរើកបាននិងបំពុងដកដង្ហើមបានអសកម្មជាបន្តបន្ទាប់ ជនរងគ្រោះអាចសន្លប់បាត់ស្មារតី ប៉ុន្តែមិនបណ្តាលឱ្យស្លាប់ទេ ។នៅក្នុងដំណាក់កាលចុងក្រោយសេចក្តីស្លាប់នៃជនរងគ្រោះអាចកើតមានឡើងក្នុងរយៈពេលពី ៤-៨ ម៉ោង ។ ត្រីប្រភេទនេះគឺ មានតម្លៃខាងសេដ្ឋកិច្ច នឹងគេហូបវាផងដែរនៅក្នុងប្រទេសជប៉ុនតែមួយគត់ដែលជាទីកន្លែងមួយវាត្រូវបានគេស្គាល់ថា ជាអាហារហ្វូហ្គូ (fugu) ហើយដែលមានបំរើជាអាហារប្រណិតពិសេសនៅក្នុងភោជនីដ្ឋាន ។ ប៉ុន្តែ ចុងភៅមិនត្រឹមតែត្រូវបានគេផ្តល់សិទ្ធិទេ ថែមទាំងត្រូវបានគេយល់ព្រមឱ្យរៀបចំត្រីនេះសំរាប់ដាក់ចានផងដែរ ។ ធម្មតាសាច់វា (ដែលមិនបង្កឱ្យមានគ្រោះថ្នាក់បានប្រសិនបើវាធ្វើកុំឱ្យប៉ះពាល់ជាតិពុលពីសរីរាង្គនិងពីស្បែករបស់វា) គឺត្រូវបានគេធ្វើជាបន្ទះស្តើងនិងហូបឆៅ ទោះយ៉ាងណាក៏ដោយ ពេលខ្លះវាត្រូវបានរំងាស់ធ្វើជាស៊ុប ។ មានចុងភៅខ្លះបានទុកសាច់ត្រីមានជាតិពុលដែលឆ្អិនមួយនាទី ដើម្បីកុំឱ្យអារម្មណ៍ និងភាពស្ពឹកជ្រាបទៅលើអណ្តាតនិងបបូរមាត់ ។ ការដឹងនៅអារម្មណគឺ ជាផ្នែកមួយនៃភាពគ្មានកង្វល់នៃការហូបត្រី (*fugu*) ហើយវាមិនមែនជារឿងធម្មតាសំរាប់ប្រជាជនជាច្រើននាក់ដែលបានស្លាប់ជារៀងរាល់ឆ្នាំដោយសារការហូបត្រីដ៏ប្រណិតនេះ ។ ប៉ុន្តែផ្ទុយទៅវិញការត្រួតពិនិត្យមើលបរិមាណជាតិពុលគឺ វាដូចជាការលេង

ល្បែងភ្នាល់បង្វិលកងមូលនៃជនជាតិរុស្ស៊ី។ នៅក្នុងការខ្វះចន្លោះចំពោះចុងភៅដែលគ្មានការផ្តល់សិទ្ធិឱ្យ ដែលនៅក្នុងប្រទេសតាមបណ្តោយទន្លេមេគង្គ (*Catch and Cuture*) ផ្តល់ជាអនុសាសន៍ថា អ្នកត្រូវតែព្រលែងត្រីប្រភេទនេះចូលទៅក្នុងទន្លេវិញ។

ការយល់ដឹងលំអិតជាងនេះទៅទៀតសូមអានៈ

Anon. 2000. Pufferfish. *Catch and Culture* Vol. 6, No. 2, Supplement 9.





Zeb Hogan





# ការប្រមូលផលទិលជុំបណ្តាក់

*មានស្ត្រីឡាវជាច្រើនប្រើប្រាស់សិទ្ធិយ៉ាងទូលំទូលាយទៅលើធនធានវារិជាតិ។ ការផ្លាស់ប្តូរអាចជួយឱ្យពួកគេបានយល់ដឹងគ្រប់គ្រាន់ពីផលប្រយោជន៍ជាយុទ្ធសាស្ត្រដឹកនាំ និងគោលនយោបាយដែលមានស្រាប់។*

ប្រជាជនឡាវភាគច្រើនរស់នៅឯតំបន់ជនបទ។ ការរស់នៅរបស់ពួកគេគឺ ផ្តត់ផ្គង់ដោយត្រីដែលពួកគេចាប់បានធ្វើជាអាហារ និងអ្វីៗផ្សេងដទៃទៀតពួកគេប្រមូលពីព្រៃប្រឹក្សា និងនៅតំបន់ដីសើម។ មានប្រូតេអ៊ិនរហូតដល់ ៩០% បានពីសត្វគឺទទួលបានមកពី ត្រី និងវារីសត្វដូចជា កង្កែប ខ្យង ក្តាម និងពពួកសត្វល្អិតរស់នៅក្នុងទឹក ជលផលគឺ ជាវិស័យមួយសំរាប់ផ្គត់ផ្គង់នៅសន្តិសុខស្បៀងអាហារយ៉ាងសំខាន់។

វិស័យជលផលផ្តល់នូវប្រាក់ចំណូលផងដែរ ដែលជាតំរូវការចាំបាច់សំរាប់ការចំណាយទៅលើថ្លៃសាលារៀន និងសំរាប់ថ្លៃសុខភាពគ្រួសារ។

